អាយុ៩-១១ឆ្នាំ

# ព្រះគម្ពីរសម្រាប់កុមារ មើលតាមរូបភាព

សញ្ញាចាស់១

## សៀវភៅអនុវត្ត



KIDS GOD WORSHIP
www.kidsworship.kr
Selah
Ministry of Christian Publishing

# ព្រះគម្ពីរសម្រាប់កុមារមើលតាមរូបភាព

## សៀវភៅអនុវត្ត សញ្ញាចាស់១

### អាយុ៩-១១ឆ្នាំ

កែសម្រួល kidsworship Selah

បកប្រែដោយ | KOMA Cambodia រចនាក្រាហ្វិក | Jeewon Park, Julio Blas ការកែសម្រួល | KOMA Cambodia

ហាមថតចម្លងទាំងស្រុង ឬផ្នែកណាមួយនៃសៀវភៅនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ

# លិបិក្រម


១. ការបង្កើតផ្ទៃមេឃ និងផែនដី ---- 6

២. អដាំ និងអេវ៉ា ---- 9

៣. កាអ៊ីន និងអេបិល ---- 13

៤. ទូកធំរបស់ណូអេ ---- 16

៥. ប្រាសាទបាបិល ---- 19

៦. លោកអប្រាហាំ ---- 22

៧. សូដុម និងកូម៉ូរ៉ា ---- 25

៨. អ៊ីសាក និងរេបិកា ---- 28

៩. យ៉ាកុប ១ (យ៉ាកុប និងអេសាវ) ---- 31

១០. យ៉ាកុប ២ (យ៉ាកុបនៅបេតអែល) ---- 35


កុមារដែលថ្វាយបង្គំព្រះជាម្ចាស់ មានសុភមង្គល

# ចូរកត់ត្រាអំពីដំណើរនៃសកម្មភាព។

ចូរផាត់ពណ៌ បន្ទាប់ពីបញ្ចប់រឿងនីមួយៗ។

ស្កេន QR
ដើម្បីចូលទៅស្ដាប់រឿង។

- រឿងទី១
- រឿងទី២
- រឿងទី៣
- រឿងទី៤
- រឿងទី៥
- រឿងទី៦
- រឿងទី៧
- រឿងទី៨
- រឿងទី៩
- រឿងទី១០

## រឿងទី១៖ ការបង្កើតផ្ទៃមេឃ និងផែនដី

**ខគម្ពីរ៖ លោកុប្បត្តិ១៖១**

កាលពីដើមដំបូងបង្អស់ ព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃ និងផែនដី ។



កាលដើមដំបូងឡើយ ផែនដីពោរពេញដោយភាពងងឹត និងគ្មានអ្វីទាំងអស់។ គឺគ្មានអ្វីទាំងអស់!
គឺមានតែព្រះជាម្ចាស់តែមួយអង្គប៉ុណ្ណោះដែលគង់នៅ ថ្ងៃទីមួយ ព្រះជាម្ចាស់បានមានបន្ទូលថា៖ «ចូរមានពន្លឺ!»
ព្រះជាម្ចាស់បានហៅពន្លឺថាជា "ថ្ងៃ" ហើយងងឹងថាជា "យប់"។
ថ្ងៃទីពីរ ព្រះជាម្ចាស់ក៏មានបន្ទូលទៀតថា៖ «ចូរឱ្យមានផ្ទៃមេឃ និងទឹក!»
រំពេចនោះ ស្រាប់តែផ្ទៃមេឃ និងទឹកសមុទ្រក៏កើតមានឡើង។
នៅថ្ងៃទីបី ព្រះជាម្ចាស់ឱ្យទឹកនៅក្រោមមេឃប្រមូលផ្តុំគ្នា លេចចេញជាដីគោក។
ហើយទ្រង់បានធ្វើឱ្យមានស្មៅ ផ្កា និងដើមឈើដុះឡើងនៅលើដីនោះ។
នៅថ្ងៃទីបួន ព្រះជាម្ចាស់ក៏មានបន្ទូលទៀតថា៖ «ចូរមានព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយនៅលើមេឃ!»
ថ្ងៃទីប្រាំ ព្រះជាម្ចាស់មានបន្ទូលទៀតថា៖ «ចូរឱ្យមានសត្វបក្សីហោះហើរនៅលើមេឃ និងមានសត្វត្រីហែលក្នុងសមុទ្រ!»។
នៅថ្ងៃទីប្រាំមួយ ព្រះជាម្ចាស់បានបង្កើតសត្វជាច្រើនដែលរស់នៅលើដី។
គ្រប់ប្រភេទសត្វទាំងអស់ បានច្រៀងសរសើរតម្កើងព្រះជាម្ចាស់។
ជាចុងក្រោយបង្អស់ ព្រះជាម្ចាស់បានសូនមនុស្សឱ្យមានលក្ខណៈដូចព្រះអង្គទ្រង់។
មនុស្សដំបូងដែលព្រះជាម្ចាស់បានសូនមកនោះ គឺឈ្មោះថា "អដាំ"។
ដល់ថ្ងៃទីប្រាំពីរ ព្រះជាម្ចាស់បានឈប់សម្រាកពីកិច្ចការងារទាំងអស់។
ដូច្នេះហើយបានជានៅថ្ងៃទីប្រាំពីរ យើងរាល់គ្នាតែងឈប់សម្រាកពីការងារ យកថ្ងៃនោះជាថ្ងៃបរិសុទ្ធដែលយើងត្រូវនឹកចាំពីព្រះជាម្ចាស់រហូតមកដល់សព្វថ្ងៃនេះ។





**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. តើព្រះជាម្ចាស់បង្កើតពិភពលោករយៈពេលប៉ុន្មានថ្ងៃ?

---

b. បន្ទាប់ពីបង្កើតមនុស្សរួច តើព្រះជាម្ចាស់បង្គាប់ទៅមនុស្សដូចម្ដេចខ្លះ?

---

c. តើអ្នកសប្បាយចិត្តទេដែលព្រះជាម្ចាស់បានបង្កើតអ្នកមក? ហេតុអ្វី?

---

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (លោកុប្បត្តិ១៖១)

> កាលពីដើមដំបូងបង្អស់ ព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃ និងផែនដី ។

**សកម្មភាពទី២** សូមគូរ និងសរសេរអំពីការបង្កើតរបស់ព្រះជាម្ចាស់ តាមថ្ងៃនីមួយៗ។

